ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# កំណត់ហេតុ

## កិច្ចប្រជុំពិភាក្សាការងារ រវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយ តំណាងអង្គការសហប្រជាជាតិប្រចាំកម្ពុជា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ថ្ងៃអង្គារ ប្រាំមួយកើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.ពីរពាន់ប្រាំរយហុកសិបប្រាំពីរ ត្រូវនឹងថ្ងៃទីដប់ប្រាំមួយ ខែមករា ឆ្នាំពីរពាន់ម្ភៃបួន វេលាម៉ោងដប់ព្រឹក នៅសាលប្រជុំខេត្តឧត្តរមានជ័យ នៃទីស្តីការក្រសួងមហាផ្ទៃ មានបើកកិច្ចប្រជុំពិភាក្សាការងាររវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយតំណាងអង្គការសហប្រជាជាតិប្រចាំកម្ពុជា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានសមាសភាពចូលរួមៈ

**ក.ភាគីគណៈកម្មាធិការជាតិ គ.ជ.ប.ជ**

១.លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
២.ឯកឧត្តម សៅ សុកៈ អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
៣.លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ
៤.ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី អគ្គស្នងការរងនគរបាលជាតិ
៥.ឯកឧត្តម ឧត្តមសេនីយ៍ឯក យ៉ែម ច័ន្ទណារុំ អគ្គលេខាធិការរង គ.ជ.ប.ជ
៦.លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ
៧.ឯកឧត្តម ឧត្តមសេនីយ៍ត្រី តែ សុថារេត អគ្គលេខាធិការរង គ.ជ.ប.ជ
៨.លោកជំទាវ ឧត្តមសេនីយ៍ទោ ស៊ឹម ផាណុំ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលចាតិ
៩.ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាង ជារិទ្ធ អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ
១០.លោក ឧត្តមសេនីយ៍ត្រី សូ សារិន តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស

**ខ.ភាគីអង្គការសហប្រជាជាតិប្រចាំកម្ពុជា**

១.លោក Joseph Scheuer ( UN Resident Coordinator )
២.លោកស្រី Alissar Chaker ( UNDP Resident Representative )
៣.លោកស្រី Roueida El Hage ( OHCHR Repretiontative )
៤.លោកស្រី Kristin Parco ( ប្រធានបេសកកម្មអង្គការ IOM ប្រចាំកម្ពុជា )
៥.លោក សុត និមល ( ប្រធានការិយាល័យ អង្គការ UNRC )

រួមទាំង លោក លោកស្រីជាសហការី និងក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សរុបចំនួន ២៤រូប ស្រី ០៨រូប ។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍លើកឡើងអំពីរចនាសម្ព័ន្ធរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងកិច្ចសហការនានាជាមួយបណ្ដាក្រសួង ស្ថាប័ន ក៏ដូចជាអង្គការដៃគូជាតិ អន្តរជាតិពាក់ព័ន្ធទាំងអស់ ជម្រាបជូន លោក Joseph Scheuer ( UN Resident Coordinator ) សហការី ។

**លោក** Joseph Scheuer ( UN Resident Coordinator ) មានមតិលើកឡើងនូវចំណាប់អារម្មណ៍ថា ការជួបពិភាក្សាការងារ ក៏ដូចជាសម្ដែងការគួរសម ជាមួយ **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នាព្រឹកនេះ ទី១. បង្ហាញអំពីកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងអង្គការសហប្រជាជាតិ ជាមួយកម្ពុជា ក៏ដូចជាគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ប៉ុន្តែនៅក្នុងរយៈពេលពីរឬបីខែចុងក្រោយនេះ មានរបាយការណ៍មួយពីថ្នាក់តំបន់ដែលអាចធ្វើឲ្យមានផលប៉ះពាល់ខ្លះដល់ស្ថាប័នយើងទាងពីរ ចំពោះរបាយការណ៍នេះជារបាយការណ៍ថ្នាក់តំបន់ដោយមិនមានការចូលរួមចំណែកពីភាគីកម្ពុជាទេ ទោះជាយ៉ាងណាក៏ដោយចំពោះកិច្ចពិភាក្សាព្រឹកនេះនឹងបន្តដំណើរទៅមុខពីព្រោះមានការងារជាច្រើនត្រូវធ្វើជាមួយគ្នា ។ លោក Joseph បានបន្តថា ជំនួបព្រឹកនេះមានប្រធានបទចំនួន០២ ដែលត្រូវពិភាក្សា ផ្លាស់ប្ដូរយោបល់ជាមួយ លោកជំទាវ ទី១.ពាក់ព័ន្ធនឹងបញ្ហាដែលយើងបានដឹងទាំងអស់គ្នា ទី២.ពិនិត្យមើលជំហានបន្ទាប់នូវអនុសាសន៍ ធ្វើដូចម្ដេចដើម្បីឲ្យកិច្ចសហប្រតិបត្តិការរបស់យើងកាន់តែល្អប្រសើរ ។ ជាការសង្កេតផ្ទាល់ខ្លួន នៅពេលដែលលោកបានមកបំពេញបេសកកម្មនៅប្រទេសកម្ពុជាអំឡុងឆ្នាំ២០១២ ឃើញថា ចំពោះប្រធានបទ នៃការជួញដូរមនុស្សនៅកម្ពុជាហាក់ដូចជាមិនទាន់មានស្ថានភាពធ្ងន់ធ្ងរទេ ពេលដែល លោក បានទទួលភារកិច្ចជាអ្នកសម្របសម្រួលនៅអង្គការសហប្រជាជាតិ ឆ្នាំ២០២២ គឺការជួញដូរមនុស្សមានភាពធ្ងន់ធ្ងរ មិនមែនតែសម្រាប់កម្ពុជាទេ គឺមាននៅក្នុងតំបន់ទាំងមូល ការងារនេះបានកើតឡើងមុនពេលរៀបចំ Submit Asian ហើយក៏ទទួលបាននូវព័ត៌មានយ៉ាងច្រើនតាមរយៈការចុះផ្សាយផ្សេងៗ ក៏ដូចជាការទទួលបានព័ត៌មានពីក្រុមការងារអង្គការសហប្រជាជាតិ ដែលបានធ្វើលើការងារនេះផងដែរ ។ ចំពោះកិច្ចសហប្រតិបត្តិការ រវាងក្រុមការងារអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា គឺពីមុនមក លោក Joseph មិនដែលបានជួបពិភក្សាការងារជាមួយ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ទេពាក់ព័ន្ធការងារនេះ ដោយសង្កេតឃើញថា កិច្ចសហប្រតិបត្តិការរវាងក្រុមការងារអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជា គ.ជ.ប.ជ មានភាពរលូន មិនមានបញ្ហាអ្វីកើតឡើងទេ ហើយយើងនឹងបន្តការងារនេះឲ្យកាន់តែជិតស្និទ្ធជាមួយគ្នាទៀត នេះគឺជាភារកិច្ចរបស់អង្គការសហប្រជាជាតិ ហើយយើងមិនព្យាយាមធ្វើអត្ថាធិប្បាយអំពីបញ្ហាផ្សេងនៅក្នុងសារព័ត៌មានទេ ។ ទាក់ទងនឹងកិច្ចសហប្រតិបត្តិការ សូមបញ្ជាក់ថា អាណត្តិស្នូលរបស់អង្គការសហប្រជាជាតិ គឺធ្វើការងារជិតស្និទ្ធជាមួយអាជ្ញាធរ រាជរដ្ឋាភិបាល ហើយបន្ថែមលើកិច្ចសហប្រតិបត្តិការនេះក៏ទទួលបាននូវសំណូមពរក៏ដូចជាយោបល់ផ្សេងៗពីរដ្ឋជាសមាជិកដទៃទៀតផងដែរមកកាន់អង្គការសហប្រជាជតិ តាមរយៈស្ថានទូត ក៏ដូចជា ការលើកជាសំណើពី សាធារណជន ឬជនរងគ្រោះ ដែលបានលើកឡើងអំពីករណីថ្មីៗមួយចំនួនដែលបានកើតឡើង ។ អង្គការសហប្រជាជាតិ គឺមានការគាំទ្រដល់ជនរងគ្រោះ ចែករំលែកព័ត៌មាន ធ្វើការងារជិតស្និទ្ធជាមួយ

បណ្ដាស្ថានទូត និងមានកិច្ចសហប្រតិបត្តិការជាមួយថ្នាក់តំបន់ ដែលថ្មីៗនេះអង្គការសហប្រជាជាតិបានចូលរួមក្នុងវេទិកាអាស៊ាន-ចិន ផងដែរ ។ លោក Joseph បានលើកឡើងថា ប្រធានបទនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់កម្ពុជា ក៏ដូចជាថ្នាក់តំបន់ ដែលបញ្ហានេះមានទំហំធំសម្រាប់យើងទាំងអស់ដោះស្រាយ ដូច្នេះសូមកុំឲ្យការយល់ច្រឡំបន្តិចបន្តួចតាមរយៈរបាយការណ៍នេះ ធ្វើឲ្យមានការប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការទេ ដំហានបន្តយើងចង់ឲ្យកិច្ចសហប្រតិបត្តិការរបស់យើងមានភាពជិតស្និទ្ធ កុំឲ្យព័ត៌មានចេញពីរបាយការណ៍នេះ ក្លាយជាឧបសគ្គដល់ដំណើរការក្នុងការដោះស្រាយបញ្ហា ដែលមានទំហំធំដែលមានចំពោះមុខ ដូចដែលមាននៅក្នុងឯកសារដូចបានបង្ហាញជូន លោកជំទាវ និងក្រុមការងារ នៃកិច្ចប្រជុំពិភាក្សា គឺជាឯកសារដែលក្រុមការងារអង្គការសហប្រជាជាតិបានធ្វើការវិភាគផ្ទៃក្នុង ហើយលោកជំទាវ នឹងឃើញនូវវិស័យ ឬផ្នែកចំនួន១៦ ដែលអង្គការសហប្រជាជាតិបានធ្វើការដោយផ្ទាល់ និងប្រយោលដើម្បីដោះស្រាយបញ្ហាទាំងអស់គ្នា ចំណែកនៅក្នុងប្រទេសកម្ពុជាយើងមិនដែលបានលើកអំពីចំនួនតួលេខនោះទេដោយសារតែមានភាពស្មុគស្មាញ និងមិនដែលហ៊ានសន្និដ្ឋានដែរប៉ុន្តែតាមរយៈរបាយការណ៍ដែលចេញផ្សាយនេះបានធ្វើឲ្យមានការយល់ច្រឡំ ដែលធ្វើឲ្យមានការប៉ះពាល់ដល់ទំនាក់ទំនងកិច្ចសហប្រតិបត្តិការរបស់យើង ហើយយើងនឹងធ្វើការជាមួយគ្នានៅក្នុងវិស័យទាំង១៦ ឬច្រើនជាងនេះទៀត ។ លោក Joseph មានមតិលើកឡើងបន្តថា យើងមិនមានចេញជារបាយការណ៍ទេ នៃកម្រិតអង្គការសហប្រជាជាតិក្នុងប្រទេសកម្ពុជា ប៉ុន្តែយើងបានរបាយការណ៍ផ្សេងៗដូចជា UNODC របាយការណ៍ដែលរៀបចំដោយឧត្តមស្នងការសិទ្ធិមនុស្សនៅហ្សឺណែវ របាយការណ៍ចេញដោយអ្នករាយការពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស របាយការណ៍ចេញដោយអគ្គលេខាធិការអង្គការសហប្រជាជាតិអំពីសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៍ទាំងអស់នេះត្រូវបានបែងចែកជូនរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងមានការព្រមព្រៀងពីរាជរដ្ឋាភិបាល ដោយមានការផ្ដួចផ្ដើមដោយរដ្ឋាភិបាលជប៉ុន តាមរយៈរបាយការណ៍ដែលទាក់ទងនឹងប្រធានបទ និងសាច់រឿងនេះ ត្រូវបានឯកភាពគ្នាថា ពិតជាកើតមានមែននៅក្នុងប្រទេសកម្ពុជា ចំពោះនៅក្នុងក្របខណ្ឌអាស៊ានយើងបានផ្លាស់ប្ដូរយោបល់ផងដែរដូចជា ប្រទេសថៃ ឥណ្ឌូណេស៊ី យើងត្រូវពិនិត្យបន្តទៀតដើម្បីពិភាក្សាក្នុងន័យស្ថាបនាឈានទៅការដោះស្រាយយ៉ាងដូចម្ដេច យើងមិនចង់ឲ្យការចុះផ្សាយនេះមានផលប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការរបស់យើងទេ ។ លោក Joseph បានបញ្ជាក់ជូនម្ដងទៀតថា ឯកសារនេះ គឺជាការវិភាគចុងក្រោយរបស់អង្គការសហប្រជាជាតិ ជាឯកសារផ្ទៃក្នុង(ពង្រាង) សូមជូនលោកជំទាវ និងក្រុមការងារពាក់ព័ន្ធផ្ដល់មតិយោបល់ ដែលនៅក្នុងឯកសារនេះក៏បានដាក់ចេញនូវអនុសាសន៍មួយចំនួនដើម្បីធ្វើការពិភាក្សាគ្នាពេលក្រោយទៀត ។

**លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍អរគុណចំពោះការបញ្ជាក់បំភ្លឺបន្ថែមអំពីគោលជំហរ និងកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ របស់ លោក Joseph Scheuer ( UN Resident Coordinator ) ។ ពាក់ព័ន្ធប្រតិកម្មនឹងការផ្សព្វផ្សាយកន្លងមក កម្ពុជាបានធ្វើក្នុងកម្រិតមួយដែលជាការផ្សព្វផ្សាយរបស់សារព័ត៌មាននានា ប៉ុន្តែអ្វីដែលកាន់តែពិបាកទទួលយកនោះ គឺជាការចេញផ្សាយពីអង្គការសហប្រជាជាតិដែលធ្វើឲ្យកម្ពុជាមានការខកចិត្ត ដែលធ្វើឲ្យមានការភ្ញាក់ផ្អើលកាន់តែខ្លាំង ពីព្រោះសកម្មភាពប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា គឺជាការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល

កម្ពុជា ដែលជាអាទិភាពចម្បងក្នុងចំណោមអាទិភាពដទៃទៀតសម្រាប់សន្តិសុខជាតិ កន្លងមកប្រជាជនកម្ពុជាបានក្លាយខ្លួនជាជនរងគ្រោះនៅក្រៅប្រទេស ប៉ុន្តែកម្ពុជាមិនដែលទម្លាក់កំហុស ឬបន្ទោសទៅលើប្រទេសណាមួយឡើយពីព្រោះ គឺជារឿងខ្វះខាតទាំងអស់គ្នារវាងប្រទេសបញ្ជូន និងប្រទេសទទួល យើងត្រូវការតែកិច្ចសហប្រតិបត្តិការ និងការផ្តល់នូវបច្ចេកទេសនានាដើម្បីកាត់បន្ថយ ដោយយើងបានដឹងច្បាស់ថាអំពើជួញដូរមនុស្ស គឺជាឧក្រិដ្ឋកម្មឆ្លងដែនដែលប្រទេសតែមួយមិនអាចធ្វើទៅបានទេ កម្ពុជាទទួលស្គាល់ថាកើតមានករណីពិតប្រាកដមែន រហូតកម្ពុជាបានបង្កើតផែនការប្រតិបត្តិការ ដោយបើកចំហរឲ្យមានការផ្តល់ព័ត៌មាន ពីគ្រប់អ្នកដែលបានដឹងនូវព័ត៌មានជាក់លាក់ដើម្បីធ្វើប្រតិបត្តិការសង្គ្រោះ និងបង្ក្រាបឲ្យបានទាន់ពេលវេលា នៅក្នុងរយៈពេល នៃការធ្វើប្រតិបត្តិការចាប់ពីខែវិច្ឆិកា ឆ្នាំ២០២២ រហូតដល់ដាច់ឆ្នាំ២០២៣ យើងបានព័ត៌មាន និងបណ្តឹងជាក់លាក់មានចំនួន ជាង ១ពាន់ករណី យើងបានប្រតិបត្តិការចំនួន ៩៧% ប៉ុន្តែមិនបានរកឃើញដូចការផ្តល់ព័ត៌មាន និងបណ្តឹងទាំងអស់នោះទេ ទោះជាយ៉ាងណា យើងនៅតែបន្តប្រតិបត្តិការក្នុងការនាំយកអ្នកដែលបានអះអាងថាជាជនរងគ្រោះចេញពីកន្លែងដែលគាត់បានរាយការណ៍ យើងបានរកឃើញជាង ២ពាន់នាក់ អ្នករងគ្រោះពិតប្រាកដមានពី ៥០ទៅ៧០ករណីប៉ុណ្ណោះ ដែលមានចំនួនជាង ២០០នាក់ ប៉ុន្តែមិនមែនសុទ្ធតែរងគ្រោះដោយអំពើជួញដូរមនុស្សទាំងស្រុងនោះទេ យើងក៏បានឆ្លើយតបគ្រប់ករណីទាំងអស់ទោះបីករណីនោះដូច ឬមិនដូចទៅនឹងការផ្តល់ព័ត៌មានក្តី កម្ពុជាមានភារកិច្ចក្នុងការស្វែងរកការពិតនៅគ្រប់ទីតាំង និងធ្វើប្រតិបត្តិការនាំយកមនុស្សចេញពីទីតាំងស្វែងរកបទល្មើសក៏ដូចជាជនល្មើសដើម្បីផ្តន្ទាទោសតាមច្បាប់ ។ កម្ពុជាតែងតែបើកកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសពាក់ព័ន្ធ ក៏ដូចជាស្ថានទូតដើម្បីទទួលស្គាល់ និងទទួលខុសត្រូវរួមគ្នាជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការជួយគាំទ្រជួយដល់ប្រជាពលរដ្ឋរបស់ពួកគាត់ដែលបានមករងគ្រោះនៅកម្ពុជា យើងតែងតែទទួលនូវការថ្លែងអំណរគុណពីបណ្តាស្ថានទូត នៃប្រទេសពាក់ព័ន្ធអំពីកិច្ចសហប្រតិបត្តិក្នុងការសង្គ្រោះ បង្ក្រាបករណីដែលកើតមាននៅក្នុងប្រទេសកម្ពុជា ដើម្បីឲ្យប្រជាពលរដ្ឋគាត់ទទួលបានសុវត្ថិភាព យើងក៏ទទួលបានព័ត៌មាន និងទំនាក់ទំនងគ្នាទៅវិញទៅមក ប៉ុន្តែអ្វីដែលជាការផ្សព្វផ្សាយរបស់សារព័ត៌មាន គឺយើងគិតថាក្រៅផ្លូវការ អ្វីដែលយើងយល់គ្នារវាងប្រទេសនឹងប្រទេស គឺការទទួលស្គាល់ដូចគ្នានូវអ្វីដែលជាការពិត យើងមិនអាចគិតថាបិទសិទ្ធិសារព័ត៌មាន ប៉ុន្តែចំពោះព័ត៌មានផ្លូវការ គឺយើងមានការប្រុងប្រយ័ត្នណាស់ ពីព្រោះកន្លងមកមានសារព័ត៌មានជាច្រើនបានផ្សព្វផ្សាយអំពីជនជាតិតៃវ៉ាន់ជាង ១០ម៉ឺននាក់ ដែលយើងមិនបានរកឃើញដល់ចំនួនរយ ឬពាន់នាក់នៅឡើយទេ ចំពោះព័ត៌មានជាង ១ពាន់ករណី គឺយើងរកឃើញត្រឹមតែចំនួនជាង ៣ពាន់នាក់តែប៉ុណ្ណោះ យើងក៏ដឹងថាកម្ពុជាមិនមែនជាប្រទេសដែលធំ ចំណែកទីតាំងធ្វើអាជីវកម្មក៏មិនច្រើនដែរ យើងក៏បានរុករកគ្រប់ទីកន្លែងទោះបីជាមានខ្វះខ្លះក៏ដោយក៏មិនអាចឈានដល់មានមនុស្ស ១សែននាក់ដែលលាក់កំបាំងដែរ រហូតមកដល់ពេលនេះយើងនៅតែបន្តប្រតិបត្តិការរុករកដូចភ្លៀងរលឹម ដរាបណានៅមិនទាន់បង្ក្រាប ឬសម្អាតអស់នូវបទល្មើស ពីកម្ពុជា ។ **លោកជំទាវ** មានប្រសាសន៍បញ្ជាក់អំពីជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថាយើងមិនមានការអាក់អន់ចិត្តក្នុងការកាត់បន្ថយកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិទេ កម្ពុជាក៏មិនបដិសេធថាគ្មានបទល្មើសកើតឡើងនៅកម្ពុជាទេ ប៉ុន្តែអ្វីដែលយើងចង់បានគឺការផ្សព្វផ្សាយនូវការពិត ពីព្រោះអាចមានការប៉ះពាល់ខ្លាំងរវាងប្រទេស និងប្រទេស ក៏ដូចជាប៉ះពាល់ដល់

ចំណូល សេដ្ឋកិច្ច ទោះបីជាទេសចរណ៍ ការផលិត ការនាំចេញ នាំចូលនូវទំនិញផ្សេងៗក៏នាំឲ្យមានផលប៉ះពាល់ ផ្ទុយទៅវិញនឹងធ្វើឲ្យមានការធ្លាក់ទឹកចិត្តចំពោះអ្នកដែលបានធ្វើការងារនេះ ទាំងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលបានធ្វើការរួមគ្នា តើយើងត្រូវធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នាយ៉ាងដូចម្តេច ដើម្បីធ្វើការងារនេះសម្រេចបានជោគជ័យ? ពីព្រោះ ២ឆ្នាំមកហើយសម្រាប់ការវាយតម្លៃលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជាទទួលបានចំណាត់ថ្នាក់លេខ៣ជាប់គ្នា មានន័យថា យើងមិនបានទទួលការលើកទឹកចិត្តក្នុងកិច្ចខិតខំប្រឹងប្រែងទេ ហាក់បីដូចមើលមិនឃើញពីការឆ្លើយតបរបស់កម្ពុជាដែលយើងអាចគិតបានថា បើមិនមានការឆ្លើយតបទេតើស្ថានភាពទៅជាយ៉ាងណា? យើងតែងតែសំណូមពរដល់ប្រទេសពាក់ព័ន្ធនានា សូមពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការជួយប្រជាពលរដ្ឋខ្លួនឯង ពីព្រោះអ្វីដែលធ្វើនៅកម្ពុជាមិនមែនមានតែប្រជាជនកម្ពុជាទេ គឺជនល្មើសក៏ជាជនបរទេស ជនរងគ្រោះក៏ជាជនបរទេស ដូច្នេះប្រទេសនានាគួរតែពង្រឹងកិច្ចការពារ និងបង្ការទប់ស្កាត់ឲ្យបានល្អជៀសវាងអំពើល្មើសនេះរីករាលដាលដល់ប្រទេសដទៃ ក្នុងតំបន់ ក៏ដូចជាក្នុងពិភពលោក ។ **លោកជំទាវ** មានប្រសាសន៍បន្តថា ចំពោះយើងខ្ញុំដែលជាក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា តែងតែប្តេជ្ញាចិត្តធ្វើយ៉ាងណាដើម្បីធ្វើឲ្យការងារយើងកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាពជាងមុន យើងខ្ញុំក៏បានពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធ ទាំងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ទាំងដៃគូអភិវឌ្ឍន៍នានា ក៏ដូចជាប្រទេសជិតខាង ក្នុងតំបន់ និងពិភពលោក ដែលយើងបានចូលរួមជាមួយ ហើយក៏សង្ឃឹមថានឹងទទួលបានកិច្ចសហប្រតិបត្តិការ និងដំបូន្មានល្អៗពីបណ្តាប្រទេសដែលមានបទពិសោធន៍ដើម្បីឲ្យការងារនេះសម្រេចបានជោគជ័យ កម្ពុជាស្វាគមន៍ចំពោះគ្រប់កិច្ចសហប្រតិបត្តិការ ហើយកម្ពុជាក៏សង្ឃឹមថាអង្គការសហប្រជាជាតិនឹងមិនបោះបង់កម្ពុជាទេ ។

**លោក** Joseph Scheuer (UN Resident Coordinator) មានមតិថ្លែងអំណរគុណចំពោះ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលបានលើកអំពីចំណុចទាំងអស់នេះឡើងមក ។ លោក Joseph បានធ្វើការឆ្លើយតបដោយចែកជា ៣ផ្នែក ចំពោះអ្វីដែល លោកជំទាវ បានលើកឡើងក្នុងចំណុចចុងក្រោយពាក់ព័ន្ធកិច្ចសហប្រតិបត្តការ គឺអង្គការសហប្រជាជាតិមិនមានគម្រោង ឬចេតនាណាមួយឡើយក្នុងការបញ្ចប់កិច្ចសហប្រតិបត្តិការជាមួយកម្ពុជានោះទេ ផ្ទុយទៅវិញអង្គការសហប្រជាជាតិមានតែបង្កើនកិច្ចខិតខំប្រឹងប្រែង ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាល ដូច្នេះហើយទើបយើងជួបប្រជុំពិភាក្សាគ្នាក្នុងថ្ងៃនេះ ដើម្បីពិនិត្យលើកិច្ចការទាំងនេះ និងធ្វើការដោះស្រាយនូវចំណុចដែលមានការយល់ច្រឡំ ។ លោក Joseph មានមតិចែករំលែកនូវការយល់ឃើញមួយចំពោះការលើកឡើងរបស់ លោកជំទាវ ពាក់ព័ន្ធការចុះផ្សាយរបស់សារព័ត៌មានជាច្រើន ព្រមទាំងវីដេអូផងដែរ សូមឯកភាពថា យើងមិនអាចផ្អាកការចេញផ្សាយរបស់សារព័ត៌មានទាំងអស់នោះបានទេ ហើយក៏មានការផ្សព្វផ្សាយជាច្រើនទាក់ទងនឹងប្រទេសភូមាពាក់ព័ន្ធបញ្ហានេះផងដែរ ។ លោក Joseph បានធ្វើការបញ្ជាក់ថា មានសារព័ត៌មានក្នុងស្រុកបានធ្វើការផ្សព្វផ្សាយខុសពីការពិត ដែលបានផ្សាយថា មានប្រជាជនកម្ពុជារងគ្រោះ១០ម៉ឺននាក់ ប៉ុន្តែតាមការសង្កេតជាក់ស្តែង គឺភាគច្រើនជាជនបរទេសមកពីបណ្តាប្រទេសផ្សេងៗ ដែលពាក់ព័ន្ធនឹងបញ្ហានេះ ហើយនៅក្នុងរបាយការណ៍ ក៏បានលើកឡើងទទួលស្គាល់ អំពីកិច្ចខិតខំប្រឹងប្រឹងប្រែងរបស់កម្ពុជាក្នុងការដោះស្រាយនូវបញ្ហានេះផងដែរ ដូច្នេះហើយ អង្គការសហប្រជាជាតិក៏មិនបានទទួលស្គាល់ចំពោះការចុះផ្សាយរបស់

សារព័ត៌មានទាំងនោះដែរដែលធ្វើឲ្យប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការរបស់យើង ហើយយើងនៅតែបន្តកិច្ចសហប្រតិបត្តិការជាមួយគ្នាកាន់តែល្អប្រសើរបន្ថែមទៀត ក្រុមការងារ ក៏បានការកោតសសើរចំពោះកម្ពុជាផងដែរក្នុងកិច្ចខិតខំប្រឹងប្រែងកន្លងមកនេះ ។ សម្រាប់ជំហានទៅមុខទៀត ដើម្បីឆ្លើយតបទៅនឹងការលើកឡើងរបស់ លោកជំទាវ ពាក់ព័ន្ធកិច្ចសហប្រតិបត្តិការទាក់ទងជាមួយ ១៦ចំណុច នៅក្នុងកាលវិភាគរបស់យើងខ្ញុំ ដូច្នេះសូមធ្វើការឆ្លើយតបអាទិភាពចំនួន ២ គឺ៖ ទី១.ការជួយទៅដល់ជនរងគ្រោះ អង្គការសហប្រជាជាតិ ជាពិសេសអង្គការ IOM ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៅកម្ពុជា នឹងធ្វើការជិតស្និទ្ធជាមួយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីជួយដល់ជនរងគ្រោះតាមរយៈការធ្វើការជាមួយបណ្តាស្ថានទូត នេះគឺជាការងារអាទិភាពមួយដែលយើងនឹងត្រូវបន្តកិច្ចសហប្រតិបត្តិការល្អនៅក្នុងការងារនេះ ហើយយើងនឹងជួបពិភាក្សាគ្នាលម្អិតដើម្បីរកការដោះស្រាយដោយយោងលើឯកសារក៏បានលើកអំពីបញ្ហានេះផងដែរ ។ លោក Joseph បានបញ្ជាក់សារជាថ្មីថា អង្គការសហប្រជាជាតិ មិនមានចេតនាណាមួយក្នុងការកាត់បន្ថយកិច្ចសហប្រតិបត្តិការទេ អាណត្តិរបស់អង្គការសហប្រជាជាតិ គឺធ្វើការជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល កាលពីខែវិច្ឆិកាថ្មីៗនេះ អង្គការសហប្រជាជាតិបានចុះហត្ថលេខាលើក្របខណ្ឌ នៃកិច្ចសហប្រតិបត្តិការរយៈពេល៥ឆ្នាំជាមួយរាជរដ្ឋាភិបាល គោលបំណងសំខាន់ គឺជួយឲ្យប្រទេសកម្ពុជា សម្រេចគោលដៅការអភិវឌ្ឍន៍របស់ខ្លួន ក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមក្នុងឆ្នាំ២០៣០ ហើយជាប្រទេសដែលមានចំណូលខ្ពស់នៅក្នុងឆ្នាំ២០៥០ ។ ប៉ុន្តែប្រធានបទដែលយើងលើកមកពិភាក្សាក្នុងថ្ងៃនេះគឺជាប្រធានបទមួយដែលអាចប៉ះពាល់ដល់ផែនការរួម ដោយសារកេរ្តិ៍ឈ្មោះប្រទេស ក៏ដូចជាកិច្ចសហប្រតិបត្តិការជាមួយប្រទេសមួយចំនួនទៀតជាដើម ដែលធ្វើឲ្យមានផលប៉ះពាល់ដល់ផែនការរួម ចក្ខុវិស័យរួមតាមការគ្រោងទុក ។

**លោកស្រី** Roueida El Hage (OHCHR Repretiontative) មានមតិចូលរួមជាមួយការលើកឡើងរបស់លោក Joseph ផងដែរលើកិច្ចខិតខំប្រឹងប្រែងរបស់ លោកជំទាវ ក៏ដូចជាគណៈកម្មាធិការជាតិ គ.ជ.ប.ជ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ។ លោកស្រី បានលើកឡើងអំពីកិច្ចប្រជុំជាមួយ លោកជំទាវ កាលពីខែកញ្ញា កន្លងមកដែលបានពិនិត្យលើផែនការសកម្មភាពដែលបានដាក់ចុះទាំង៦ចំណុច ដែលផែនការទាំងនោះមានការឯកភាពពី សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កាលពីពីអាណត្តិមុន ហើយទទួលបាននូវលទ្ធផលល្អជាច្រើន និងសូមកោតសរសើរចំពោះគណៈកម្មាធិការជាតិ ដែលបានខិតខំប្រឹងប្រែងធ្វើការឆ្លើយតបទៅនឹងការណែនាំរបស់ឧត្តមស្នងការសិទ្ធិមនុស្ស ដែលមានចំនួន១៥ទំព័រ ទាក់ទងប្រធានបទនេះ ។ លោកស្រីបានលើកឡើងបន្តថា តាមរយៈកិច្ចសហប្រតិបត្តិការនេះ នៅក្នុងរបាយការណ៍របស់ ឯកឧត្តមអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយបានបញ្ជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស គឺបានរំលេចឡើងចំនួន៣ កថាខណ្ឌ លើកឡើងបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា នៅក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំពោះរបាយការណ៍ទាំងនេះក្រសួងការបរទេសសហរដ្ឋអាម៉េរិកក៏បានទទួលស្គាល់ផងដែរ នៅក្នុងរបាយការណ៍នោះក៏បានពឹងផ្អែកទាំងស្រុកទៅលើធាតុចូលរបស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ សូមធ្វើកោតសរសើរម្តងទៀតចំពោះ លោកជំទាវ ហើយចំពោះតួលេខ និងទិន្នន័យទាំងអស់នេះនឹងមានការចេញផ្សាយរៀងរាល់៦ខែម្តង សង្ឃឹមថាយើងនឹងទទួលបាននូវតួលេខ ទិន្នន័យជាបន្តបន្ទាប់ដែលអាចយកទៅប្រើប្រាស់លើកក្រោយបាន ។ លោកស្រី បានបញ្ជាក់ថា

របាយការណ៍ទាំងអស់នេះ គឺយោងលើរបាយការណ៍របស់ ឯកឧត្តម អគ្គលេខាធិការអង្គការសហប្រជាជាតិ យើងមិនពឹងផ្អែកលើរបាយការណ៍ ឬទិន្នន័យណាផ្សេងឡើយ ប៉ុន្តែមានខ្លឹមសារស្រដៀងនឹងខ្លឹមសារចេញដោយ UNODC ផងដែរ ។ លោកស្រី ក៏បានបញ្ជាក់អំពីខ្លឹមសារនូវចំណុចដែលបានសរសេរនៅក្នុង របាយការណ៍នោះ ប្រហែលជាមានការយល់ច្រឡំនៅពេលដែលមានការបកស្រាយបន្ថែមទៀត ដែលនៅក្នុងខ្លឹមសារនោះ សូម្បីឈ្មោះប្រទេសកម្ពុជាក៏មិនបានលើកឡើងផងដែរ អ្វីដែលលើកឡើង គឺសំដៅទៅលើតំបន់ទាំងមូលតែម្តង.ចំណែកខ្លឹមសារនៅក្នុងសារព័ត៌មាន ហាក់មិនបានផ្តោតលើរបាយការណ៍របស់ អគ្គលេខាធិការអង្គការសហប្រជាជាតិទេ មិនដឹងថាគាត់មានចេតនាយ៉ាងណានោះទេ ទាំងនេះគឺជាការយល់ច្រឡំ ហើយយើងនឹងបន្តកិច្ចសហប្រតិបត្តិការជាមួយគ្នាទៀត ។ ចំណុចបន្ថែមដែល លោកស្រី ចង់បញ្ជាក់ប្រាប់ពាក់ព័ន្ធការរៀបចំរបាយការណ៍នេះថា សេចក្តីព្រាងខ្លឹមសាររបាយការណ៍ត្រូវបានបញ្ជូនទៅទីក្រុងហ្សឺណែវ កាលពីថ្ងៃទី៥ ខែមិថុនា ដើម្បីសុំយោបល់ ប៉ុន្តែមិនបានទទួលយោបល់ណាមួយត្រឡប់មកវិញនោះទេ ប្រសិនបើ លោកជំទាវ និងក្រុមការងារ ទទួលបានយោបល់ខ្លះៗ ប្រហែលខ្លឹមសារមួយចំនួន គឺយើងបានកែសម្រួលរួមគ្នារួចទៅហើយ ពីព្រោះការផ្ញើរបាយការណ៍ជូននៅថ្ងៃទី០១ ខែមិថុនា រហូតចុងខែសីហា ទើបចេញចុងក្រោយហើយក៏មិនបានទទួលបាននូវការប្រឹក្សា ឬយោបល់ណាមួយដែរ ។

**លោកស្រី** Kristin Parco (ប្រធានបេសកកម្មអង្គការ IOM ប្រចាំកម្ពុជា) មានមតិសម្តែងនូវការកោតសរសើរជាថ្មីម្តងទៀតចំពោះគណៈកម្មាធិការជាតិ គ.ជ.ប.ជ អង្គការសហប្រជាជាតិបានធ្វើការយ៉ាងជិតស្និទ្ធជាក្រុមការងារទាំង៦ របស់គណៈកម្មាធិការជាតិ តាំងពីមុនការឆ្លងជំងឺកូវីដ ក្នុងការរីករាលដាលជំងឺកូវីដ រហូតមកដល់ពេលនេះយើងបានធ្វើការជាមួយគ្នាលើ Online Scamming យើងមានកិច្ចសហប្រតិបត្តិការជាច្រើនក្នុងការអនុវត្តការងារជាមួយគ្នាបន្តទៀត ។ ពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងក្នុងកិច្ចប្រជុំនាពេលនេះ គឺធ្វើយ៉ាងណាឲ្យមានយល់គ្នាច្បាស់ ដើម្បីបន្តកិច្ចសហប្រតិបត្តិការជាមួយគ្នាទៅមុខទៀត ដោយ លោកស្រី Kristin បានបញ្ជាក់បន្ថែមថា ដោយសារគណៈកម្មាធិការជាតិបានរៀបចំផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំបន្ត ដូច្នេះនេះជា ឱកាសដែល លោកជំទាវ ផ្តល់ព័ត៌មាន ឬស្នើសុំថាតើផ្នែកណាទៀតដែលអង្គការសហប្រជាជាតិអាចជួយបានក្នុងន័យកិច្ចសហប្រតិបត្តិការ នេះជាចំណុចសំខាន់មួយក្នុងការ ។ ដោយសារមានករណីមួយចំនួនដែលអង្គការ សហប្រជាជាតិ បានទទួល ដូច្នេះសូមការណែនាំពី លោកជំទាវ ថាតើយើងត្រូវធ្វើការសម្របសម្រួលករណីនោះយ៉ាងដូចម្តេច? និងត្រូវសម្របសម្រួលក៏ដូចជាធ្វើការដោះស្រាយយ៉ាងណា? សូមអរគុណ ។

**លោកស្រី** Alissar Chaker (UNDP Resident Representative) មានមតិលើកឡើងថា អង្គការ UNDP ធ្វើកិច្ចការងារនេះនៅក្នុងថ្នាក់តំបន់ជាពិសេសតាមរយៈគណៈកម្មាធិការ Commit ដោយមានការចូលរួមពីបណ្តាប្រទេសនៅតំបន់ទន្លេមេគង្គ ដូចជាប្រទេសចិន ឡាវ ថៃ ភូមា កម្ពុជា វៀតណាម ដោយសារយន្តការនេះមានសារៈសំខាន់ដែលត្រូវមានកិច្ចពិភាក្សាគ្នារវាងប្រទេសជាសមាជិកទន្លេមេគង្គ ជាមួយប្រទេសចិន ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ថ្មីៗនេះ បានដឹងថាមានការជួបប្រជុំពិភាក្សារវាងមន្ត្រីជាន់ខ្ពស់ SOMTC និងបានអញ្ជើញភាគីប្រទេសចិនចូលរួមផងដែរ ដោយ លោកស្រី បានយល់ឃើញថា ប្រទេសចិន មិនទាន់ចូលជាសមាជិករបស់ SOMTC នៅឡើយទេ ទោះបីជាគណៈកម្មាធិការនេះតូចជាងអាស៊ាន

ប៉ុន្តែមាននូវយន្តការដាក់លាក់សម្រាប់ប្រទេសនៅក្នុងតំបន់ទន្លេមេគង្គ ។ ទាំងនេះ គឺជាអ្វីដែលអង្គការ UNDP បាន ចូលរួមចំណែក និងប្តេជ្ញាចិត្តក្នុងការផ្តល់ព័ត៌មានបន្ថែមទៀត ហើយសូមលើកទឹកចិត្តដល់គណៈកម្មាធិការជាតិ គ.ជ.ប.ជ មានការចូលរួមជាមួយ COMMIT ក៏ដូចជា SOMTC សូមអរគុណ ។

**លោក** Joseph Scheuer ( UN Resident Coordinator ) មានមតិសង្ខេបអំពីអ្វីដែលបានលើកឡើងទាំងអស់ជូន លោកជំទាវ និងក្រុមការងារនៅពេលនេះថា អាណត្តិរបស់អង្គការសហប្រជាជាតិ គឺធ្វើការជាមួយតាមរយៈរាជរដ្ឋាភិបាល ហើយទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិដែលមានវត្តមាននៅទីនេះរួមមាន តំណាង UNODC UNICEF រួមទាំងការិយាល័យទទួលបន្ទុកជនភៀសខ្លួន ។ លោក Joseph បានស្នើសូមឲ្យ លោកជំទាវ និងក្រុមការងារគណៈកម្មាធិការជាតិ ពិនិត្យលើឯកសារជាសេចក្តីព្រាងដែលបានចែកជូន សូមផ្តល់យោបល់ ដំបូន្មានល្អៗ ដែលនឹងមានជាកិច្ចពិភាក្សាបន្តបន្ទាប់ទៀតក្នុងការយល់គ្នា និងដោះស្រាយបញ្ហារួមគ្នា ហើយក៏ជាវេទិកាមួយសម្រាប់កិច្ចពិភាក្សាអំពីកិច្ចសហប្រតិបត្តិការនៅឆ្នាំ២០២៤ នឹងអាចមានអ្វីដែលថ្មីដើម្បីពិនិត្យរួមគ្នា ។

**ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាង ធារិទ្ធ** អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ មានមតិឆ្លើយតបនឹងសំណួររបស់ លោកស្រី Kristin Parco ចាប់ពីខែសីហា ឆ្នាំ២០២២ កម្ពុជាបានពង្រឹងយន្តការ ការងារស្រាវជ្រាវសង្គ្រោះជនបរទេសដែលមានបណ្តឹងចូលមករាជរដ្ឋាភិបាលកម្ពុជា យើងបានបង្កើតយន្តការ ដើម្បីទទួលព័ត៌មានទូលំទូលាយពីមជ្ឈដ្ឋានទូទៅ គ្រប់ព័ត៌មានដែលទទួលបានទោះបីគ្រប់ជ្រុងជ្រោយ ឬមិនគ្រប់ក៏ដោយ យើងតែងតែមានវិធានការ និងធ្វើប្រតិបត្តិការភ្លាម យើងបានដឹងគ្រប់គ្នាហើយថាកម្ពុជាបើកទូលាយក្នុងការទទួលព័ត៌មានតាមរយៈ Facebook Hotline របស់អគ្គស្នងការដ្ឋាននគរបាលជាតិ មិនត្រឹមតែទទួយតាម Hotline ថែមទាំងមានការទទួលព័ត៌មាននានាតាមរយៈមន្ត្រីពាក់ព័ន្ធទូទៅផងដែរ រាល់ព័ត៌មានដែលទទួលបាន គឺយើងមិនបានទុកចោលនោះទេ ដូច្នេះមុននឹងធ្វើការឆ្លើយតប ឯកឧត្តម សូមធ្វើការបង្ហាញអំពីស្ថិតិមួយចំនួនដែលបានអនុវត្តក្នុងឆ្នាំ២០២៣ យើងទទួលបានបណ្តឹងពីជនបរទេសចំនួន ៦៣៣សំណើរ បន្ថែម ១៥ថ្ងៃ នៃខែមករា ឆ្នាំ២០២៤នេះផងដែរ អ្នកប្តឹងចំនួន ១៥៤៥នាក់ ស្រី១៧៩នាក់ ២៣សញ្ជាតិ យើងបានរកឃើញចំនួន ៣៨២ករណី រកឃើញមនុស្ស ៩៨៦នាក់ ស្រី១១៧នាក់ មាន១៩សញ្ជាតិ រកឃើញជាក់ស្តែងតាមបណ្តឹងចំនួន ៣១ករណី ក្នុងចំណោមបណ្តឹងទាំងអស់ ប៉ុន្តែវាមិនមែនជាករណីជួញដូរមនុស្សទាំងអស់ទេ មានករណីបង្ខាំងចំនួន ១៦ករណី ករណីជួញដូរមនុស្ស ១៥ករណី អ្វីដែលមិនពិតដូចបណ្តឹងចំនួន៣៥០ករណី ចំនួន ២០២ទៀតយើងមិនបានរកឃើញទេ ដោយសារបណ្តឹងមិនមានប្រភពច្បាស់លាស់ មិនមានព័ត៌មានជាក់ស្តែង ។ ឆ្លើយតបនឹងការលើកឡើង ដើម្បីយើងធ្វើការងារទទួលបានជោគជ័យបន្តទៀត គឺយើងរក្សានូវគោលនយោបាយ និងយន្តការបើកចំហរក្នុងការទទួលព័ត៌មានទូលំទូលាយ យើងមិនទុកព័ត៌មាននោះចោលដោយមិនមានចំណាត់ទេ ទោះបីព័ត៌មាននោះទទួលបានជាផ្លូវការ ឬក្រៅផ្លូវការក៏ដោយ គឺយើងនឹងមានចំណាត់ការរហូត ប្រសិនបើមានមតិយោបល់ដើម្បីអភិវឌ្ឍលើយន្តការនេះឲ្យមានប្រសិទ្ធភាពបន្ថែមទៀត យើងខ្ញុំសូមទទួលស្វាគមន៍ក្នុងការផ្តល់នូវបទពិសោធន៍ល្អៗ ពាក់ព័ន្ធយន្តការដែលកម្ពុជាកំពុងអនុវត្តនេះ ជឿជាក់ថានៅមិនទាន់មានប្រទេសនៅលើពិភពលោកណាមួយបានធ្វើនៅឡើយទេ ដូច្នេះអ្វីដែលបានចេញផ្សាយកន្លងមក និងអ្វីដែលកម្ពុជាបានធ្វើហាក់មិនទាន់បានឆ្លុះបញ្ចាំងគ្នានៅឡើយទេ ហើយក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ដែលយើងបានជួបពិភាក្សាស្វែងយល់ពីគ្នា និងមានឱកាសទទួលបានការបកស្រាយ និងពន្យល់ចំពោះសេចក្តីព្រាងមួយនេះ ។

**លោកជំទាវ ជុំ ប៊ុនរ៉ុង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ថ្លែងអំណរគុណជាថ្មីចំពោះ លោក Joseph ព្រមទាំងភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ដែលបានជួបពិភាក្សាដ៏មានសារៈសំខាន់នេះ ។ **លោកជំទាវ** បានលើកឡើងថា អ្វីដែលបានពិភាក្សាគ្នានៅពេលនេះ យើងនឹងធ្វើការពិភាក្សាគ្នាឲ្យបានស៊ីជម្រៅបន្ថែមទៀត ចំពោះតួនាទីភារកិច្ចរបស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ គឺ ទី១.តាមដានភាពប្រែប្រួល នៃបទល្មើសដែលកើតមាននៅកម្ពុជា ក៏ដូចជានៅក្នុងតំបន់ និងពិភពលោក ទី២.ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីស្វែងរកដំណោះស្រាយឲ្យមានប្រសិទ្ធភាពជាងមុន ជាពិសេសការពង្រឹងលើការអនុវត្ត នៃកិច្ចព្រមព្រៀង អនុស្សរណៈទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសពាក់ព័ន្ធ ដើម្បីរំលឹកឡើងវិញថាត្រូវធ្វើដូចម្តេចដើម្បីឲ្យមានប្រសិទ្ធភាព ហើយយើងនឹងដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ នឹងត្រៀមបញ្ចប់នៅក្នុងត្រីមាសទី១ ឆ្នាំ២០២៤ ដែលសព្វថ្ងៃនេះ យើងកំពុងតែធ្វើការវាយតម្លៃបញ្ចប់ផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ នឹងបន្តរៀបចំអនុវត្តផែនការថ្មី ទី៣.ពង្រឹងយន្តការដែលបានរៀបចំនៅក្នុងអាណត្តិថ្មីរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នេះ ដែលកំពុងតែកែសម្រួលនៅក្នុងរចនាសម្ព័ន្ធដើម្បីលើកកម្ពស់សមត្ថភាព ទី៤.ជំរុញការអនុវត្តសកម្មភាព ដោយមានកិច្ចសហប្រតិបត្តិការពីគ្រប់ភាគីពាក់ព័ន្ធលើយុទ្ធសាស្ត្រទាំង៤ ទាំងអស់នេះនឹងកើតមានឡើងជាលទ្ធផលនៅក្នុងឆ្នាំ២០២៤ ។

ចុងបញ្ចប់ នៃកិច្ចប្រជុំពិភាក្សា **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ថ្លែងអំណរគុណចំពោះអង្គការសហប្រជាជាតិទាំងអស់ ដែលបានប្តេជ្ញាចិត្តក្នុងកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស យើងនឹងយល់គ្នាកាន់តែច្បាស់នៅពេលយើងធ្វើការជាមួយគ្នាកាន់តែជិតស្និទ្ធ ។

កិច្ចប្រជុំពិភាក្សាការងាររវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយតំណាងអង្គការសហប្រជាជាតិប្រចាំកម្ពុជា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបញ្ចប់នៅវេលាម៉ោង ដប់មួយ និងសាមសិបនាទី ថ្ងៃខែឆ្នាំដដែល ទទួលបានផ្លែផ្កា និងលទ្ធផលល្អប្រសើរ ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី១៨ខែ មករា ឆ្នាំ២០២៤

**អ្នកធ្វើកំណត់ហេតុ**

វរសេនីយ៍ឯក សៅ ស៊ីនួន

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃចន្ទ ១១កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៉ុណ្ណ សំខាន់

បានឃើញ
01/02/24